## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ: ០៤៧.ស.ខល

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការវិភាគមន្ទីរពិសោធន៍រកឃើញអ្នកមានវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មី លើអ្នកដំណើរជនជាតិបរទេសចំនួន ០៣នាក់ និង ការណែនាំត្រើនរំលឹកអនុវត្តន៍វិធានការការពារការចម្លងវីរុសកូវីដ-១៩ នៅកម្ពុជា

យោងតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសុខាភិបាល សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា រាជរដ្ឋាភិបាលកម្ពុជា កំពុងតែយកចិត្តទុកដាក់ខ្ពស់លើការវិវត្តនៃការរាតត្បាតជំងឺកូវីដ-១៩ ជាពិសេសលើពពួកនៃវីរុសកូវីដ-១៩ ដែលបានបំប្លែងខ្លួនថ្មី (new variant) ដែលអ្នកវិទ្យាសាស្ត្រវេជ្ជសាស្ត្រ បានរកឃើញជាបណ្តើរៗ និងដែលបានលើកឡើងរួមគ្នាជាមួយអង្គការសុខភាពពិភពលោក ពីភាពឆ្លងសាហាវ ហើយលឿន និងធ្ងន់ធ្ងរជាងវីរុសកូវីដ-១៩ ដែលកំពុងមានការរាតត្បាតបច្ចុប្បន្ននៅក្នុងប្រទេស នៅក្នុងតំបន់ និងនៅលើសកលលោកយើងនេះ។ ជាក់ស្តែង តាមព័ត៌មានទទួលបានពីអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា នាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ មានការរាយការណ៍ពីករណីឆ្លងវីរុសកូវីដ-១៩ ដែលបានបំប្លែងខ្លួនថ្មី (ប្រភេទ B.1.1.7) ប្រមាណជា ៨០ប្រទេសហើយនៅលើសកលលោកនេះ ហើយមានប្រមាណជាជាង ៣០០ករណី រកឃើញនៅក្នុងបណ្តាប្រទេសជាង ១០ប្រទេសនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច ត្រូវបានរកឃើញមានវត្តមានវីរុសកូវីដ-១៩ ដែលបានបំប្លែងខ្លួនថ្មី (ប្រភេទ B.1.1.7) និងចំនួន ៨ ប្រទេស/កន្លែង ដែលបានរាយការណ៍ពីករណីឆ្លងវីរុសកូវីដ-១៩ ដែលបានបំប្លែងខ្លួនថ្មី (ប្រភេទ 501Y.V2) ដែលនៅក្នុងចំណោមបណ្តាប្រទេសទាំងនេះ ក៏មានប្រទេសដែលនៅក្នុងតំបន់អាស៊ាន និងនៅជិតខាងកម្ពុជាដែរ។ ប្រមាណជាលើសពី ៤០ប្រទេស និងទីតាំងនៅលើពិភពលោក បានរាយការណ៍ពីការរកឃើញករណីឆ្លងប្រភេទ 501Y.V2 variant ដែលនៅក្នុងនេះ មានចំនួនប្រមាណជា ៤ប្រទេស នៅតំបន់ប៉ាស៊ីហ្វិកខាងលិច បានរកឃើញលើសពី ៧០ករណីហើយ។ ដោយឡែក នៅលើសកលលោក ប្រមាណជាលើសពី ១០ប្រទេស/ទីតាំងហើយដែរ ដែលបានរកឃើញករណីឆ្លងប្រភេទ P.1 variant ដែលក្នុងចំណោមនេះ នៅតំបន់ប៉ាស៊ីហ្វិកខាងលិច មានរបាយការណ៍លើសពី ០២ករណីឆ្លងវីរុសប្រភេទថ្មីនេះ ពីប្រទេសចំនួន ០២ ផងដែរ (ដែលគេមិនបានបញ្ចេញឈ្មោះប្រទេសទាំងនេះឡើយ ដោយហេតុផល កំពុងស្រាវជ្រាវបន្តទៀត)។ អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋកម្ពុជា មានការប្រុងប្រយ័ត្នខ្ពស់ ការពារខ្លួនកុំធ្វេសប្រហែសឱ្យសោះ និងមិនត្រូវមើលរំលង ពីលទ្ធភាពនៃការចម្លងវីរុសកូវីដ-១៩ ប្រភេទបំប្លែងថ្មីទាំងនេះ មកក្នុងសហគមន៍កម្ពុជាយើងនោះឡើយ។

ជាក់ស្តែង ដោយមានការពង្រឹងប្រព័ន្ធរុករកស្រាវជ្រាវ ជាមួយនឹងការធ្វើវិភាគមន្ទីរពិសោធន៍ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានរាយការណ៍ពីការវិភាគរកឃើញករណីឆ្លងវីរុសកូវីដ-១៩ ថ្មី ដែលបានបំប្លែងខ្លួនថ្មី (ប្រភេទ UK variant 20I/501Y.V1, VOC 202012/01 និង B.1.1.7) ក្នុងចំណោមអ្នកដំណើរដែលចូលមកកម្ពុជា មានដូចតទៅ៖



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

១. បុរសជនជាតិឥណ្ឌា អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌា បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។

២. ស្ត្រីជនជាតិឥណ្ឌា អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌា បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។

៣. ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសណ្ឋាគារសុខា ជាអ្នកធ្វើដំណើរមកពីប្រទេសចិន បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១។

បច្ចុប្បន្ន អ្នកជំងឺទាំងបីនាក់ខាងលើនេះ ត្រូវបានដាក់ឱ្យព្យាបាលនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន រាជធានីភ្នំពេញ រួចហើយ។

ដោយសង្កេតឃើញថា បងប្អូនប្រជាពលរដ្ឋយើង ហាក់ភ្លេចខ្លួនអំពីហានិភ័យដ៏ធំធេងនៃការចម្លងវីរុសកូវីដ-១៩ ជាពិសេសនៅក្នុងបរិបទនៃការបំប្លែងខ្លួនជាបន្តបន្ទាប់របស់វីរុសដ៏កាចសាហាវនេះ ដោយមានការជួបជុំគ្នាច្រើនកុះករនៅក្នុងពិធីជប់លៀង ពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យទានផ្សេងៗ និងការធ្វើដំណើរកំសាន្តទៅកាន់ស្រុកកំណើត ឬទីរមណីយដ្ឋាននានា ដោយមិនបានអនុវត្តតាមវិធានការណែនាំរបស់ក្រសួងសុខាភិបាលដែលបានធ្វើជារឿយៗឡើយ។ ដូច្នេះ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការក្រើនរំលឹកសារជាថ្មីម្តងទៀត ជូនដល់សាធារណជនទាំងអស់ឲ្យបានជ្រាបថា វីរុសកូវីដ-១៩ ជាពិសេសវីរុសបាន និងកំពុងតែបំប្លែងខ្លួនថ្មីជាច្រើនប្រភេទ កំពុងតែចរាចរបន្តរាតត្បាតនៅលើសកលលោកយ៉ាងខ្លាំងក្លា ដូចបានជម្រាបជូនខាងលើនេះស្រាប់។ ដូច្នេះ យើងមិនត្រូវមើលស្រាលលើលទ្ធភាពចម្លងរហ័ស និងភាពសាហាវធ្ងន់ធ្ងរបណ្តាលមកពីការវាយលុកនៃជំងឺកូវីដ-១៩ លើសរីរាង្គមនុស្សយើងនោះឡើយ ហើយសភាពចម្លងខ្លាំងក្លា និងភាពធ្ងន់ធ្ងរនៃជំងឺនេះ អាចកើតមានឡើងនៅក្នុងប្រទេសយើង គ្រប់ពេលវេលា គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង ប្រសិនបើបុគ្គលមិនបានការពារខ្លួនត្រឹមត្រូវនោះទេ។ សូមបុគ្គលគ្រប់រូប ចងចាំ និងចូលរួមអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួនជានិច្ច នូវវិធានការការពារខ្លួនសាមញ្ញៗ និងត្រូវបន្តប្រុងប្រយ័ត្នផ្ទាល់ខ្លួនពីការឆ្លងជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យខាងតែបាននូវវិធានការណ៍ បីកុំ និង បីការពារ ដែលមានដូចខាងក្រោម៖

**ត្រូវអនុវត្ត វិធានការ ៣ការពារ ជាប់ជាប្រចាំ**

១. ត្រូវលាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ឬទឹកអាកុល ឬអាកុលជែលឱ្យបានលើសពី ២០ដងក្នុងមួយថ្ងៃ។

២. ត្រូវពាក់ម៉ាស់ ត្រូវខ្ទប់មាត់ និងច្រមុះ នៅពេលក្អក កណ្តាស់ ដោយប្រើម៉ាស់ ប្រើកែងដៃ ឬប្រើក្រដាស់ជូតមាត់ ហើយត្រូវបោះចោលក្នុងធុងសម្រាមបិទជិតត្រឹមត្រូវ។

៣. ត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គលឲ្យបានយ៉ាងតិច ១.៥ ម៉ែត្រឡើង ទៅពីម្នាក់ទៅម្នាក់។

**ត្រូវអនុវត្ត វិធានការ ៣កុំ**

១. កុំទៅកន្លែងដែលមានមនុស្សម្នាច្រើនកុះករ ឬការជួបជុំគ្នាច្រើន ឬពិធីដែលមានមនុស្សច្រើនពេក (Avoid crowded places)។

២. កុំទៅកន្លែងដែលបិទជិតឈឹង មិនមានខ្យល់ចេញចូលគ្រប់គ្រាន់ ហើយប្រើម៉ាស៊ីនត្រជាក់ច្រើនពេក (Avoid close settings)។

៣. កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំឱបគ្នា កុំកៀកស្មាគ្នា នៅពេលជួបភ្ញៀវ ជាពិសេសនៅកន្លែងដែលមានមនុស្សនិយាយគ្នាច្រើន ហើយស្ថិតនៅជិតគ្នាពេក ហើយត្រូវប្រើវិធីសំពះគ្នា លើកដៃជាសញ្ញា ឬងក់ក្បាលជាដើម (Avoid close contacts) និងត្រូវរក្សាចម្ងាយពីគ្នាមួយម៉ែត្រកន្លះឡើងទៅ (Social and individual distancing)។

អាជ្ញាធរថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ស្រុក ក្រុង ខ័ណ្ឌ រដ្ឋបាលឃុំ/សង្កាត់) ត្រូវចាត់តាំងកម្លាំងមានសមត្ថកិច្ចគ្រប់គ្រង ឃ្លាំមើល និងធ្វើការណែនាំការអនុវត្តវិធានការការពារនៅតាមតំបន់របស់ខ្លួន ជាពិសេសនៅ

តាមទីផ្សារ រមណីយដ្ឋាន ភោជនីយដ្ឋាន ទីកន្លែងសាធារណៈនានា ឲ្យបានហ្មត់ចត់ដើម្បីជៀសផុតពីការឆ្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍យើង និងត្រូវយកចិត្តទុកដាក់ពង្រឹងការងារធ្វើចត្តាឡីស័កកុំឱ្យមានរបូតចេញពីសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ដោយអនុវត្តន៍តាមការណែនាំដូចខាងក្រោមនេះ ៖

យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមសារសម្លេងនាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រសួងសុខាភិបាល សូមធ្វើការណែនាំជូនដល់អាជ្ញាធររាជធានី-ខេត្ត មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត និងផ្នែកដែលពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ នូវចំនុចសំខាន់ៗមានដូចខាងក្រោមនេះ ៖

១. ត្រូវបង្កើនការយកចិត្តទុកដាក់ និងចាត់កម្លាំងមានសមត្ថកិច្ច ធ្វើការឃោមកាម និងត្រួតពិនិត្យឱ្យបានហ្មត់ចត់ជាទីបំផុត នូវការអនុវត្តវិធានការចត្តាឡីស័កចំនួន ១៤ថ្ងៃ សម្រាប់គ្រប់អ្នកដំណើរមកពីក្រៅប្រទេស នៅតាមច្រកចូលមកកម្ពុជា នៅតាមព្រំដែននានានៅទូទាំងប្រទេស (ទាំងច្រកអាកាស ច្រកជើងគោក និងច្រកជើងទឹក)។

២. អាជ្ញាធរមានសមត្ថកិច្ច ដែលមានភារកិច្ចឈរជើងនៅតាមច្រកចូលមកកម្ពុជាទាំងអស់ ត្រូវអនុវត្តន៍ការត្រួតពិនិត្យអ្នកដំណើរចូលមកកម្ពុជា ឱ្យបានម៉ឺងម៉ាត់ច្បាស់លាស់ ដោយមិនអនុញ្ញាតឱ្យមាន "មេខ្យល់" នាំអ្នកដំណើរគេចវេះចាកចេញពីច្រកចូលណាមួយ ដោយមិនបានធ្វើចត្តាឡីស័កនោះឡើយ។

៣. ត្រូវមានការអប់រំជាប្រចាំ ដោយដាក់មេក្រូ ផ្សាយអំពីតម្រូវការនៃការធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ សម្រាប់អ្នកដំណើរដែលចូលមកកម្ពុជា និងផ្សព្វផ្សាយពីទោសទណ្ឌ ដែលមានចែងនៅក្នុងអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ដែលនឹងត្រូវអនុវត្តន៍ជាចាំបាច់ នៅពេលដែលមានបុគ្គលណាមិនអនុវត្តន៍តាមវិធានការសុខាភិបាលនៅតាមច្រកចូល នេះ។

៤. ត្រូវស្វែងរកឱ្យឃើញ នូវ "មេខ្យល់" នេះ ប្រសិនបើមានការរបូតអ្នកដំណើរណាម្នាក់ ឬក្រុមអ្នកដំណើរ ចូលមកក្នុងប្រទេស នូវអ្នកដំណើរដែលមិនបានធ្វើចត្តាឡីស័កគ្រប់ចំនួន ១៤ថ្ងៃ នៅតាមខេត្ត ឬស្រុក ដែលមានច្រកចូលមកកម្ពុជា ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ដែលមានជាធរមាន។

៥. ប្រសិនបើមានព័ត៌មានអំពីអ្នកដំណើរណាម្នាក់ ឬក្រុមអ្នកដំណើរ ដែលមិនបានធ្វើចត្តាឡីស័កនៅតាមខេត្ត ឬស្រុក ដែលមានច្រកចូលមកកម្ពុជា មកដល់ខេត្ត ស្រុក សង្កាត់ ឃុំ ភូមិណាមួយ សូមអាជ្ញាធរខេត្ត ស្រុក សង្កាត់ ឃុំ ភូមិនោះ ត្រូវរាយការណ៍ជាបន្ទាន់ជូនគណៈកម្មការខេត្តប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅខេត្តនោះ និងរាយការណ៍ជូនគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ហើយត្រូវតែចាត់ចែងដាក់ពួកគាត់ឱ្យធ្វើចត្តាឡីស័កឱ្យបានគ្រប់ចំនួន ១៤ថ្ងៃ នៅហ្នឹងកន្លែង ទៅតាមការរៀបចំរបស់អាជ្ញាធរខេត្តនោះជាបន្ទាន់ និងត្រូវយកវត្ថុសំណាកពួកគាត់ ដោយក្រុមការងារឆ្លើយតបបន្ទាន់របស់មន្ទីរសុខាភិបាលខេត្តនោះ ដើម្បីធ្វើវិភាគ ឱ្យបានរហ័សផងដែរ។

៦. ត្រូវតាមដានសុខភាពអ្នកដំណើរដែលធ្វើចត្តាឡីស័ក ដោយក្រុមគ្រូពេទ្យនៃមន្ទីរសុខាភិបាលរាជធានី-ខេត្ត ទៅតាមនិយាមប្រតិបត្តិបច្ចេកទេស និងកត់ត្រាត្រឹមត្រូវ ។

៧. អ្នកដំណើរដែលបានរកឃើញថា មិនបានធ្វើចត្តាឡីស័កនៅតាមខេត្ត ឬស្រុកដែលមានច្រកចូលមកកម្ពុជានោះ ត្រូវរៀបចំឱ្យមានការសាកសួរព័ត៌មានដ៏ល្អិតល្អន់ជាទីបំផុត (ដោយមិនត្រូវមានការលាក់លៀម) នូវមូលហេតុនៃការមិនបានធ្វើចត្តាឡីស័កនៅតាមទីកន្លែងដែលមានច្រកចូលមកកម្ពុជា បុគ្គលណាដែលជាអ្នកនាំផ្លូវឱ្យគេចវេះពីការធ្វើចត្តាឡីស័ក មធ្យោបាយធ្វើដំណើរ ចេញដំណើរពីកន្លែងណា និងឈប់នៅកន្លែងណាខ្លះ ហើយមានប្រាស្រ័យទាក់ទងជាមួយបុគ្គលណាខ្លះនៅតាមផ្លូវដែលខ្លួនធ្វើដំណើរ ការធ្វើដំណើរមានរយៈពេលប៉ុន្មានម៉ោង ប៉ុន្មានថ្ងៃ ពេលដែលមកដល់ផ្ទះ ឬកន្លែងដែលបុគ្គលនោះកំពុងតែស្នាក់នៅ មានប៉ះពាល់ជាមួយអ្នកណាខ្លះជាដើម។ ត្រូវកត់ត្រាទុកនូវព័ត៌មានទាំងនេះ ឱ្យបានត្រឹមត្រូវ ដោយត្រូវមានទាំងអាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង របស់បុគ្គលម្នាក់ៗដែលបានជួប ឬប៉ះពាល់ជាមួយអ្នកដំណើរដែលមិនបានធ្វើចត្តាឡីស័កនៅទីកន្លែងដែលមានច្រក



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

ចូលមកកម្ពុជានេះ ជាចាំបាច់។ ត្រូវរាយការណ៍នូវព័ត៌មានទាំងនេះ មកមន្ទីរសុខាភិបាលរាជធានី-ខេត្ត ដែលអ្នកដំណើរនោះកំពុងស្នាក់នៅ ដើម្បីប្រមូលផ្តុំនូវព័ត៌មានទាំងនេះ ប្រសិនបើមានតម្រូវការធ្វើការរុករកស្រាវជ្រាវនៅពេលដែលអ្នកដំណើររូបនោះ មានលទ្ធផលវិជ្ជមានវីរុសកូវីដ-១៩។

៨. ការដាក់អ្នកដំណើរដែលមិនទាន់បានធ្វើចត្តាឡីស័ក ឱ្យស្នាក់នៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅតាមទីតាំងដូចបានជម្រាបជូនខាងលើ នីតិវិធី ការគ្រប់គ្រង និងការផ្គត់ផ្គង់ភស្តុភារ ជូនដល់អ្នកធ្វើចត្តាឡីស័កនៅតាមទីតាំងនីមួយៗ គឺធ្វើឡើងដោយអាជ្ញាធរថ្នាក់ក្រោមជាតិ រីឯក្រុមគ្រូពេទ្យ ត្រូវទទួលបន្ទុកការងារតាមដានសុខភាពរបស់អ្នកធ្វើចត្តាឡីស័ក ទៅតាមនីតិប្រតិបត្តិបច្ចេកទេសសុខាភិបាលត្រឹមត្រូវ ហើយរាយការណ៍នូវរាល់បាតុភាពសុខភាព ជូនអាជ្ញាធរខេត្ត និងជូនក្រសួងសុខាភិបាល ឱ្យបានឆាប់ដែលអាចធ្វើទៅបាន ដើម្បីអាចទទួលបានជំនួយគាំទ្របច្ចេកទេសសមស្របបានទាន់ពេលវេលា។

៩. បងប្អូនប្រជាពលរដ្ឋ និងអាជ្ញាធរសង្កាត់ ឃុំ ភូមិ សូមចូលរួមរាយការណ៍ជូនសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ មកបុគ្គល មកក្រុមគ្រួសារខ្លួន និងកុំឱ្យមានការចម្លងនៅក្នុងសហគមន៍របស់ខ្លួន។

បើអ្នកសង្ស័យថា មានករណីឆ្លងជំងឺកូវីដ-១៩ ដោយមានគ្រុនក្តៅ យ៉ាងតិច៣៧.៥ អង្សាសេ និងមានរោគសញ្ញាមួយយ៉ាងតិចក្នុងចំណោម ក្អក ហៀរសំបោរ ឈឺបំពង់ក ដង្ហើមខ្លី និងពិបាកដកដង្ហើម ហត់ **និងមាន**ប្រវត្តិធ្វើដំណើរឆ្លងខេត្តនៅក្នុងប្រទេស ឬក្រៅពីប្រទេសកម្ពុជាក្នុងអំឡុងពេល ១៤ថ្ងៃ មុនចេញរោគសញ្ញា សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍លេខ ១១៥។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តនៃបញ្ហាសុខភាព តាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រនេះ មានសំភារៈអប់រំសុខភាពដែលអាចទាញយកមកមើលបាន និងទំព័រហ្វេសប៊ុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។

សំរាប់ព័ត៌មានបន្ថែម៖ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ ១១៥ ទោះគ្មានថវិកាក្នុងទូរស័ព្ទរបស់អ្នកក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនងមកក្រសួងសុខាភិបាល តាមលេខ៖០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃចន្ទ ០៤កើត ខែផល្គុន ឆ្នាំជូត ទោស័ក ពស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**